ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

និយ័តករបរធនបាលកិច្ច
TRUST REGULATOR

**និយ័តករបរធនបាលកិច្ច**

លេខ: ០៣៤/២៣ ន.ប.ធ. /ស.ជ.ណ.

## សេចក្តីជូនដំណឹង

## ស្តីពី

## ការទទួលចុះឈ្មោះចូលរួមវគ្គបណ្តុះបណ្តាល និងការប្រឡងគុណវុឌ្ឍិ ក្នុងវិស័យបរធនបាលកិច្ច លើកទី៤

និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) មានកិត្តិយសសូមជម្រាបជូនដំណឹងដល់បុគ្គលត្រូវទទួលស្គាល់គុណវុឌ្ឍិក្នុងវិស័យបរធនបាលកិច្ច សម្រាប់ក្រុមហ៊ុនបរធនបាល, ក្រុមបរធនបាលនៃបរធនបាលកិច្ចហិរញ្ញវត្ថុ, បរធនបាលរូបវន្តបុគ្គលឯករាជ្យ, ប្រតិបត្តិករបរធនបាលផ្តល់សេវារក្សាសុវត្ថិភាព ឬសេវារក្សាទុក (Escrow Services) ក្នុងវិស័យបរធនបាលកិច្ច, ក្រុមហ៊ុនវាយតម្លៃក្នុងវិស័យបរធនបាលកិច្ច និងសាធារណជនទាំងអស់មេត្តាជ្រាបថា÷ **ន.ប.ធ.** នឹងចាប់ផ្តើមទទួលពាក្យចុះឈ្មោះចូលរួមកម្មវិធីវគ្គបណ្តុះបណ្តាល និងការប្រឡងគុណវុឌ្ឍិក្នុងវិស័យបរធនបាលកិច្ច លើកទី៤ **ចាប់ពីថ្ងៃជូនដំណឹងនេះតទៅ រហូតដល់ថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២៣**។ អាស្រ័យហេតុនេះ បុគ្គលដែលត្រូវចូលរួម ឬមានបំណងចូលរួមវគ្គបណ្តុះបណ្តាលនេះ សូមអញ្ជើញមកចុះឈ្មោះ និងបង់ថ្លៃចូលរួមវគ្គបណ្តុះបណ្តាលនេះនៅនិយ័តករបរធនបាលកិច្ច ដែលមានទីតាំងនៅអគារអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (ជាន់ទី៨) អាសយដ្ឋានផ្លូវ ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ។ សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនងតាមរយៈលេខទូរសព្ទតេលេក្រាម ០៩៦ ៧៤០ ៨៨៩៣/ ០៧៧ ២៧៨ ០១៥/ ០១០ ៤១៥ ៥២០ ឬអ៊ីមែល÷ info@trustregulator.gov.kh ។

**បញ្ជាក់÷** ចំពោះវគ្គបណ្តុះបណ្តាល និងការប្រឡងគុណវុឌ្ឍិនេះ ត្រូវបង់ថ្លៃចូលរួមចំនួន ៨០០,០០០៛ (ប្រាំបីរយពាន់រៀល) ក្នុងមួយនាក់។ សូមទាញយកពាក្យស្នើសុំតាមរយៈតំណភ្ជាប់មួយនេះ÷ https://shorturl.at/fqJW4 ឬតាមរយៈ QR Code ខាងក្រោម (សូមភ្ជាប់មកជាមួយនូវអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែនថតចម្លង ១ ច្បាប់)។

**សម្គាល់÷** ចំពោះកាលបរិច្ឆេទក្នុងការរៀបចំកម្មវិធីវគ្គបណ្តុះបណ្តាល និងការប្រឡងគុណវុឌ្ឍិក្នុងវិស័យបរធនបាលកិច្ច លើកទី៤ **ន.ប.ធ.** នឹងជម្រាបជូនតាមក្រោយ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណជន និងបុគ្គលត្រូវទទួលស្គាល់គុណវុឌ្ឍិទាំងអស់ជ្រាបជាព័ត៌មាន។

ថ្ងៃ ចន្ទ ២រោច ខែ អស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧
រាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ២០២៣
**និយ័តករបរធនបាលកិច្ច**

**សូមទាញយកពាក្យស្នើសុំនៅទីនេះ**